ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ...........៧៦៩..........ក.ប/ស.ជ.ណ.រ.ដ.ប

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បេក្ខជនទាំងអស់ឱ្យបានជ្រាបថា **លទ្ធផលជាប់ជាស្ថាពរ និងជាប់បម្រុង នៃការប្រឡងជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌថ្មីកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ នៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នឹងបិទប្រកាសនៅទីស្តីការក្រសួង និងវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ១៤:០០ នាទីរសៀលនេះ។**

ដោយឡែកដើម្បីឱ្យមានតម្លាភាពចំពោះបេក្ខជន ដែលបានប្រឡងជាប់ជាស្ថាពរ នៅទីស្តីការក្រសួង (ថ្នាក់កណ្តាល) ចំនួន **០៦នាក់** ក្រសួងនឹងធ្វើការរៀបចំបែងចែកប៉ុស្តិ៍ និងជ្រើសរើសកន្លែងបម្រើការងាររបស់មន្ត្រីនីមួយៗ ដោយទុកឱកាសឱ្យអ្នកដែលមានចំណាត់ថ្នាក់ខ្ពស់ និងថ្នាក់បន្តបន្ទាប់ មានសិទ្ធិជ្រើសរើសប៉ុស្តិ៍ (អង្គភាពដែលខ្លួនចង់ទៅបម្រើការងារ)រៀងៗខ្លួន។ ដូចនេះសូមបេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរទាំងអស់ (ទីស្តីការក្រសួង និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត) ត្រូវចូលរួមប្រជុំស្តាប់ការណែនាំ និងបំពេញឯកសារផ្សេងៗ ជាមួយនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក **នាថ្ងៃសុក្រ ទី០១ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ០៩:០០ នាទីព្រឹក នៅសាលប្រជុំ B ទីស្តីការក្រសួង។**

❖ **បញ្ជាក់៖ ចំពោះបេក្ខជនដែលអវត្តមាន មិនបានចូលរួមតាមការអញ្ជើញនេះ ក្រសួងចាត់ទុកថាឯកភាពតាមការចាត់តាំងរបស់ក្រសួង ដោយមិនអាចតវ៉ាឬស្នើសុំផ្លាស់ប្តូរនៅពេលក្រោយបានឡើយ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម បេក្ខជន ទាំងអស់ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រី**
**អនុរដ្ឋលេខាធិការ និងជា**
**អនុប្រធានគណៈកម្មការរៀបចំការប្រឡង**

**ចាប ឫទ្ធិ**

ព័ត៌មានបន្ថែមសូមទំនាក់ទំនង:
- លោក ប៉ក់ ហឿន ០១១ ៩៤៣ ១៣៧
- លោក ងួន ឆេង ០១២ ៧៣៣ ៤១១
- លោក គួយ គឿន ០៧៧ ៥១៨ ៥១១